ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៨១៣.០២២.២១៧.ស.ជ.ណ

ថ្ងៃ ចន្ទ ១២កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០២២

# សេចក្តីជូនដំណឹង
## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៩ ឆ្នាំ២០២២
## ស្តីពី "ដំណើរឆ្ពោះទៅកាន់ការស្តារឡើងវិញ និងភាពធន់ក្រោយកូវីដ-១៩"

ឈឈឈ✵ឍឍឍ

វិបត្តិជំងឺកូវីដ-១៩បានធ្វើឱ្យភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងសង្គមកាន់តែធ្ងន់ធ្ងរនៅតាមបណ្តាប្រទេសនានា។ រយៈពេល និងទំហំនៃផលប៉ះពាល់អាស្រ័យទៅលើសមត្ថភាពរបស់ប្រទេសនីមួយៗក្នុងការឆ្លើយតបទៅនឹងវិបត្តិ ដែលផ្សាភ្ជាប់ជាមួយនឹងស្ថានភាពសង្គមនិងសេដ្ឋកិច្ចមុនពេលមានវិបត្តិ ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ សមត្ថភាពបច្ចេកទេសនិងហិរញ្ញវត្ថុចំពោះការអនុវត្តគោលនយោបាយគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញ ហើយសំខាន់ជាងនេះគឺការទទួលបានវ៉ាក់សាំង។ ជាលទ្ធផល ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានប្រាក់ចំណូលទាបជាច្រើនបាននិងកំពុងប្រឈមនឹងការស្តារសេដ្ឋកិច្ចឡើងវិញ ដោយប្រទេសទាំងនោះកំពុងព្យាយាមស្វែងរកមធ្យោបាយដើម្បីគាំទ្រការវិនិយោគ លើកកម្ពស់ឌីជីថលូបនីយកម្ម អនុវត្តកំណែទម្រង់ជារចនាសម្ព័ន្ធជាដើម។

កម្ពុជាក៏មិនខុសពីប្រទេសដទៃទៀតដែរ។ ដើម្បីសម្រេចបាននូវការស្តារឡើងវិញដោយរលូននិងកំណើនប្រកបដោយចីរភាព រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ និងកំណែទម្រង់ផ្សេងៗដើម្បីការពារវិស័យងាយរងគ្រោះបំផុត និងគាំទ្រដល់វិស័យដែលមានសក្តានុពលក្នុងគោលបំណងលើកកម្ពស់ផលិតភាពរបស់ពួកគេ។ ទន្ទឹមនេះ វិស័យឯកជនក្នុងគោលដៅជួយរាជរដ្ឋាភិបាលជំរុញសកម្មភាពសេដ្ឋកិច្ចដែលកំពុងមានដំណើរការ ក៏បានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនផងដែរ។ ស្ថាប័នហិរញ្ញវត្ថុ ជាពិសេសធនាគារនៅតែមានតួនាទីសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានដល់សេដ្ឋកិច្ចនិងគាំទ្រការស្តារសេដ្ឋកិច្ចឡើងវិញ។ ដើម្បីជំរុញការស្រាវជ្រាវលើបញ្ហាទាំងនេះ ធនាគារជាតិនៃកម្ពុជាបានជ្រើសរើសប្រធានបទស្រាវជ្រាវឆ្នាំនេះសម្រាប់សន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៩ ឆ្នាំ២០២២ ស្តីពី៖ **"ដំណើរឆ្ពោះទៅកាន់ការស្តារឡើងវិញ និងភាពធន់ក្រោយកូវីដ-១៩"។**

បេក្ខជនដែលមានចំណាប់អារម្មណ៍អាចផ្ញើខ្លឹមសារស្រាវជ្រាវសង្ខេប សំណើស្រាវជ្រាវ ឬអត្ថបទស្រាវជ្រាវពេញលេញអមជាមួយប្រវត្តិរូបសង្ខេបមកកាន់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីពិនិត្យលក្ខណៈសម្បត្តិ។ ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការគាំទ្រព្រមទាំងការប្រឹក្សាយោបល់ចំពោះអត្ថបទស្រាវជ្រាវដែលត្រូវបានទទួលយក។ បន្ទាប់ពីការស្រាវជ្រាវត្រូវបានបញ្ចប់ ធនាគារជាតិនៃកម្ពុជានឹងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៩ នៅខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងពង្រឹងបណ្តាញទំនាក់ទំនងក្នុងការងារស្រាវជ្រាវ។ សន្និសីទនេះ ក៏មានការចូលរួមពីអ្នកជំនាញ អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិផងដែរ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**កាលបរិច្ឆេទសំខាន់ៗ៖**

- ការផុតកំណត់នៃការទទួលសំណើស្រាវជ្រាវ៖ **ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២**
- ការជូនដំណឹងស្តីពីសំណើស្រាវជ្រាវដែលត្រូវបានជ្រើសរើស៖ **ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២២**
- ការផុតកំណត់នៃការទទួលអត្ថបទស្រាវជ្រាវពេញលេញ៖ **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២**
- ការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៩៖ **ខែវិច្ឆិកា ឆ្នាំ២០២២។**

ធនាគារជាតិនៃកម្ពុជានឹងជ្រើសរើសយកអត្ថបទស្រាវជ្រាវដែលមានគុណវុឌ្ឍិដើម្បីចូលរួមធ្វើបទបង្ហាញនៅក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៩នេះ។ ម្ចាស់អត្ថបទស្រាវជ្រាវដែលបានធ្វើបទបង្ហាញនៅក្នុងសន្និសីទនឹងទទួលបាននូវរង្វាន់លើកទឹកចិត្ត ហើយអត្ថបទស្រាវជ្រាវនឹងត្រូវបានបោះផ្សាយជាកាលិកបត្រស្រាវជ្រាវរបស់ធនាគារជាតិនៃកម្ពុជា។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ១១ ៦១១ ២១៧ / ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ macroconfer@nbc.org.kh

បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B13.022.217.INF

*Phnom Penh, March 14, 2022*

**Announcement**

**9th NBC Annual Macroeconomic Conference 2022**

**"Towards a Post-COVID-19 Recovery and Resilience"**

ឃឃឃ❀ឃឃឃ

The COVID-19 pandemic has aggravated economic and social vulnerabilities across the countries. The duration and depth of the impact depend on individual countries' abilities to respond to the pandemic crisis, which are highly associated with the pre-crisis social and economic conditions, the severity of the impact, technical and financial capacities to rollout policies supporting the recovery, and more importantly the access to vaccines. As a result, many developing and low-income countries have been struggling with the path to recovery. To take initial steps down the road to recovery from COVID-19, several countries have been trying to find ways to support investment, promote digitalization, implement structural reforms and so on.

Cambodia is no different to the rest of the world. To achieve smooth recovery and sustainable growth, the Royal Government has introduced various measures and reforms to protect the most vulnerable and support the potential sectors with an aim to enhance their productivities. In the meantime, the private sector, in supporting the state to boost ongoing economic activities, has also stepped up its efforts. The financial institutions, banks in particular, remain the key players in financing the real economy and supporting recovery. To promote research on these issues, the National Bank of Cambodia is delighted to select this year's research theme for the 9th Macroeconomic Conference 2022: **"Towards a Post-COVID-19 Recovery and Resilience"**.

The National Bank of Cambodia would like to invite interested researchers to submit an abstract, a research proposal, or a complete draft of the paper along with a CV, to the Economic Research and International Cooperation department. The National Bank of Cambodia will provide support and consultation on the selected papers. After completion of the research, NBC will organize the 9th macroeconomic conference in November 2022 to disseminate the results of the research as well as to promote networking in the research area. The conference will be attended by experts, researchers, and other national and international stakeholders.



P.O Box 25,#88 Street 102 Corner Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
Phone : + 855 23 722563
Fax/Phone : + 855 23 426117

**Important deadlines:**

| | |
|---|---|
| Submission of proposals/papers: | **March 31, 2022** |
| Announcement of selected proposals/papers: | **April 15, 2022** |
| Submission of complete drafts of papers: | **September 30, 2022** |
| The 9th Annual Macroeconomic Conference: | **November 2022** |

Only the final papers that are deemed satisfactory will be selected for the presentation at the conference. Authors presenting their papers at the conference will be rewarded, and their papers will be published in NBC's working paper series.

**CONTACT :**
Communication Office of National Bank of Cambodia
Phone Number: (855) 11 611 217 / 23 990 196
Email: macroconfer@nbc.org.kh

**Official Channels of the National Bank of Cambodia:**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA